00743435

E122

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 22 / 09 / 2011
ម៉ោង (Time/Heure): 11:00
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: Ratanak

**អង្គជំនុំជម្រះសាលាដំបូង**
Trial Chamber
Chambre de première instance

សំណុំរឿងលេខ: ០០២/១៩ កញ្ញា ២០០៧/អវតក/អជសដ
Case File/Dossier No. 002/19-09-2007-ECCC/TC

| | |
|---|---|
| ចំពោះមុខ: | ចៅក្រម **និល ណុន** ជាប្រធាន |
| | ចៅក្រម Silvia CARTWRIGHT |
| | ចៅក្រម **យ៉ា សុខន** |
| | ចៅក្រម Jean-Marc LAVERGNE |
| | ចៅក្រម **ធូ មណី** |
| កាលបរិច្ឆេទ: | ថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ២០១១ |
| ភាសាដើម: | ខ្មែរ/អង់គ្លេស/បារាំង |
| ចំណាត់ថ្នាក់ឯកសារ: | សាធារណៈ |

# សេចក្តីសម្រេចលើអញ្ញត្រកម្មនានារបស់មេធាវីការពារក្តី (អាជ្ញាយុកាលនៃបទឧក្រិដ្ឋតាមច្បាប់ជាតិ)

**សហព្រះរាជអាជ្ញា**

ជា លាង
Andrew CAYLEY

**ជនជាប់ចោទ**

នួន ជា
អៀង សារី
អៀង ធីរិទ្ធ
ខៀវ សំផន

**សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី**

ពេជ អង្គ
Elisabeth SIMONNEAU FORT

**មេធាវីជនជាប់ចោទ**

សុន អរុណ
Michiel PESTMAN
Victor KOPPE
អាង ឧត្តម
Michael G. KARNAVAS
ផាត់ ពៅស៊ាង
Diana ELLIS
ស សុវាន
Jacques VERGÈS

## ១. សេចក្ដីផ្ដើម

១. អង្គជំនុំជម្រះសាលាដំបូងបានទទួលអញ្ញត្រកម្មមួយចំនួនដែលធ្វើឡើងដោយមេធាវីការពារក្ដី អៀង សារី, អៀង ធីរិទ្ធ, ខៀវ សំផន និង នួន ជា ដែលបានដាក់ជាបន្តបន្ទាប់នៅថ្ងៃទី ១៤ និងថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ២០១១។ អញ្ញត្រកម្មទាំងនេះពាក់ព័ន្ធទៅនឹងចិរវេលានៃអាជ្ញាយុកាលដែលអាចអនុវត្តបានចំពោះបទល្មើសទាំងឡាយ នៅក្នុងក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៥៦ ("ក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦") ដែលបទល្មើសនីមួយៗត្រូវបានចោទប្រកាន់យោងតាមក្រមព្រហ្មទណ្ឌនេះ[១]។ ជនជាប់ចោទទាំងអស់បានលើកឡើងថា យុត្តាធិការរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ("អ.វ.ត.ក") ទៅលើបទល្មើសទាំងអស់នេះត្រូវបានរារាំងដោយសារការផុតរលត់អាជ្ញាយុកាលដែលមានចែងនៅក្នុងក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦ និងថា រយៈពេលនេះមិនត្រូវបានពន្យារដោយមាត្រា ៣ (ថ្មី) នៃច្បាប់ អ.វ.ត.ក នោះទេ[២]។ ការិយាល័យសហព្រះរាជអាជ្ញា ("ក.ស.ព") និងសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីបានដាក់ចម្លើយតបទៅនឹងអញ្ញត្រកម្មទាំងនេះជាបន្តបន្ទាប់នៅថ្ងៃទី ០៧ និងថ្ងៃទី ២១ ខែ មីនា ឆ្នាំ ២០១១[៣]។

---

[១] "អញ្ញត្រកម្មរបស់មេធាវីការពារក្ដីអ្នកស្រី អៀង ធីរិទ្ធ" ឯកសារ E44 ចុះថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ២០១១ ("អញ្ញត្រកម្មរបស់អ្នកស្រី អៀង ធីរិទ្ធ") កថាខណ្ឌ ៩, ២០ ដល់ ២៤។ "អញ្ញត្រកម្មបឋមស្ដីពីការរលត់បណ្ដឹងអាជ្ញា (បទឧក្រិដ្ឋថ្នាក់ជាតិ)" ឯកសារ E47 ចុះថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ២០១១ ("អញ្ញត្រកម្មរបស់ ខៀវ សំផន")។ "អញ្ញត្រកម្មរួមបញ្ចូលគ្នា" ឯកសារ E51/3 ចុះថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ២០១១ ("អញ្ញត្រកម្មរបស់ នួន ជា") កថាខណ្ឌ ៤១។ "សេចក្ដីសង្ខេបអញ្ញត្រកម្មតាមវិធាន ៨៩ របស់លោក អៀង សារី និងការជូនដំណឹងពីការមិនគោរពតាមអនុស្សរណៈក្រៅផ្លូវការនានានាពេលអនាគតដែលត្រូវបានចេញជំនួសឲ្យសេចក្ដីសម្រេចមានសំអាងហេតុរបស់តុលាការដែលជាកម្មវត្ថុបណ្ដឹងសាទុក្ខ" ឯកសារ E51/4 ចុះថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ២០១១ ("អញ្ញត្រកម្មរបស់ អៀង សារី") កថាខណ្ឌ ២៨ ("អញ្ញត្រកម្មរួមរបស់មេធាវីការពារក្ដីលើបទឧក្រិដ្ឋថ្នាក់ជាតិ")។

[២] មាត្រា ៣ (ថ្មី) នៃច្បាប់ អ.វ.ត.ក ប្រគល់ឲ្យ អ.វ.ត.ក នូវអំណាចក្នុងការនាំយកមកជំនុំជម្រះនូវជនសង្ស័យទាំងអស់ដែលបានប្រព្រឹត្តបទឧក្រិដ្ឋដែលមានចែងក្នុងក្រមព្រហ្មទណ្ឌ ឆ្នាំ ១៩៥៦ ទាក់ទងនឹងការធ្វើមនុស្សឃាត ការធ្វើទារុណកម្ម និងការវាយប្រហារលើសាសនា នៅចន្លោះថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ និងថ្ងៃទី ៦ ខែ មករា ឆ្នាំ ១៩៧៩។ ជាដំបូងបទប្បញ្ញត្តិនេះបានពន្យារអាជ្ញាយុកាលចំពោះការចោទប្រកាន់លើបទឧក្រិដ្ឋទាំងអស់នេះត្រឹមរយៈពេល ២០ឆ្នាំ និងបន្ទាប់មកថែមរយៈពេល ១០ឆ្នាំទៀត ("ច្បាប់ស្ដីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដើម្បីកាត់សេចក្ដីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ" ចុះថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០០១ ដោយបញ្ចូលវិសោធនកម្មដែលត្រូវបានប្រកាសឲ្យប្រើនៅថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ២០០៤ (នស/រកម/១០០៤/០០៦) ("ច្បាប់ អ.វ.ត.ក"))។

[៣] "ចម្លើយតបរួមរបស់ភាគីដើមបណ្ដឹងរដ្ឋប្បវេណីចំពោះសារណារបស់ក្រុមភាគីការពារក្ដីទាក់ទងនឹងអញ្ញត្រកម្ម (វិធាន ៨៩)" ឯកសារ E51/5/4 ចុះថ្ងៃទី ០៧ ខែ មីនា ឆ្នាំ ២០១១។ "ចម្លើយតបរួមរបស់សហព្រះរាជអាជ្ញាទៅនឹងអញ្ញត្រកម្មរបស់មេធាវី



សេចក្ដីសម្រេចលើអញ្ញត្រកម្មនានាស្ដីពីអាជ្ញាយុកាលនៃបទឧក្រិដ្ឋតាមច្បាប់ជាតិ/ថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ២០១១/សាធារណៈ

២. អង្គជំនុំជម្រះបានទទួលញត្តិបន្ថែមទៀតដែលធ្វើឡើងដោយមេធាវីការពារក្តី អៀង សារី ចុះថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ២០១១ ដោយបានស្នើសុំឱ្យលុបចោលនូវផ្នែកខ្លះនៃដីកាដំណោះស្រាយដោយសារផ្នែកទាំងនោះមានវិការៈ[៤]។ សហព្រះរាជអាជ្ញាបានឆ្លើយតបទៅនឹងញត្តិនេះ នៅថ្ងៃទី ១៦ ខែ មីនា ឆ្នាំ ២០១១[៥]។ នៅក្នុងសេចក្តីសម្រេចនេះ អង្គជំនុំជម្រះសម្រេចផងដែរលើញត្តិនេះដោយសារសំណើសុំរបស់មេធាវីការពារក្តី អៀង សារី គឺទាក់ទិនទៅនឹងបទល្មើសនានាដែលមាននៅក្នុងក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦ ("បទឧក្រិដ្ឋតាមច្បាប់ជាតិ")[៦]។

## ២. ប្រវត្តិនីតិវិធី

៣. ជាការឆ្លើយតបទៅនឹងអញ្ញត្រកម្មស្រដៀងគ្នានៅក្នុងសំណុំរឿង ០០១ អង្គជំនុំជម្រះសាលាដំបូងបានប្រកាសថា នៅពេលដែលមិនមានសម្លេងភាគច្រើនគាំទ្រ អង្គជំនុំជម្រះមិនអាចពិចារណាលើពិរុទ្ធភាព ឬភាពគ្មានពិរុទ្ធរបស់ជនជាប់ចោទពាក់ព័ន្ធទៅនឹងបទឧក្រិដ្ឋជាតិនោះទេ[៧]។ ការគ្មានសម្លេងភាគច្រើនគាំទ្រតាមការតម្រូវបង្កើតបានជាឧបសគ្គចំពោះការបន្តការចោទប្រកាន់លើ

---

ការពារក្តី ដោយអនុលោមតាមវិធាន ៨៩" ឯកសារ E51/5/3/1 ចុះថ្ងៃទី ២១ ខែ មីនា ឆ្នាំ ២០១១ ("ចម្លើយតបរបស់សហព្រះរាជអាជ្ញា")។

[៤] "ញត្តិរបស់ អៀង សារី ស្នើសុំលុបចោលផ្នែកខ្លះនៃដីកាដំណោះស្រាយដោយសារកំហុសនីតិវិធី" ឯកសារ E58 ចុះថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ២០១១ កថាខណ្ឌ ៣ ដល់ ៦ ("ញត្តិរបស់ អៀង សារី ស្នើសុំលុបចោលផ្នែកខ្លះនៃដីកាដំណោះស្រាយ")។

[៥] "ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងញត្តិរបស់ អៀង សារី ស្នើសុំលុបចោលផ្នែកខ្លះនៃដីកាដំណោះស្រាយដោយសារកំហុសផ្នែកនីតិវិធី" ឯកសារ E58/1 ចុះថ្ងៃទី ១៦ ខែ មីនា ឆ្នាំ ២០១១ កថាខណ្ឌ ១ ដល់ ៧, ១៨ ដល់ ១៩ ("ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងញត្តិរបស់ អៀង សារី ស្នើសុំលុបចោលផ្នែកខ្លះនៃដីកាដំណោះស្រាយ")។

[៦] *សូមមើលបន្ថែមទៀត* ចម្លើយតបរបស់អង្គជំនុំជម្រះសាលាដំបូងទៅនឹងសំណើសុំជាច្រើនបន្ទាប់ពីកិច្ចប្រជុំរៀបចំសវនាការ ឯកសារ E74 ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ២០១១ ("អង្គជំនុំជម្រះបានទទួលនូវសំណើសុំជាច្រើនទាក់ទងនឹងការជំទាស់ទៅលើការមិនអាចទទួលយកបាននូវផ្នែកខ្លះនៃដីកាដំណោះស្រាយ ឬបញ្ហានៅដំណាក់កាលស៊ើបអង្កេត [... រួមទាំងសំណើសុំឱ្យ] លុបចេញនូវផ្នែកខ្លះនៃដីកាដំណោះស្រាយ [...]។ វាមានភាពច្បាស់លាស់ដែលថាអង្គជំនុំជម្រះត្រូវជំនុំជម្រះទៅតាមដីកាដំណោះស្រាយ [...] ប្រសិនបើមានភាពមិនច្បាស់លាស់នៅដំណាក់កាលនៃការជំនុំជម្រះ អង្គជំនុំជម្រះនឹងពិចារណាតាមករណីនីមួយៗដោយធ្វើការបកស្រាយអត្ថន័យនៃដីកាដំណោះស្រាយ ដោយការបកស្រាយនេះនឹងចងកាតព្វកិច្ចអង្គជំនុំជម្រះ")។

[៧] មាត្រា ១៤ (ថ្មី) នៃច្បាប់ អ.វ.ត.ក ចែងថា "ការសម្រេចសេចក្តីដោយអង្គជំនុំជម្រះវិសាមញ្ញរបស់សាលាដំបូង តម្រូវឱ្យមានការបោះឆ្នោតគាំទ្រពីចៅក្រមបួនរូបយ៉ាងតិច"។

ជនជាប់ចោទចំពោះបទឧក្រិដ្ឋតាមច្បាប់ជាតិ នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងនៅក្នុងករណីនោះ[៨]។

៤. នៅក្នុងរឿងក្ដីនេះ ដីកាដំណោះស្រាយដែលបានចេញដោយសហចៅក្រមស៊ើបអង្កេត ("ក.ស.ច") បានចោទប្រកាន់ជនជាប់ចោទចំនួនបួនរូប ថាបានប្រព្រឹត្តបទឧក្រិដ្ឋតាមច្បាប់ជាតិនៃការធ្វើមនុស្សឃាត ការធ្វើទារុណកម្ម និងការវាយប្រហារលើសាសនា[៩]។ អង្គជំនុំជម្រះសាលាដំបូងបានទទួលសំណុំរឿង ០០២ នៅថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១១ បន្ទាប់ពីមានសេចក្ដីសម្រេចរបស់អង្គបុរេជំនុំជម្រះ លើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ[១០]។ បន្ទាប់ពីអញ្ញត្រកម្មនានាត្រូវបានដាក់នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង កាលពីខែ កុម្ភៈ ឆ្នាំ ២០១១ រួចមក អង្គជំនុំជម្រះបានណែនាំឱ្យការិយាល័យសហព្រះរាជអាជ្ញាដាក់សេចក្ដីសន្និដ្ឋានបន្ថែម ដើម្បីគាំទ្រដល់ការអះអាងរបស់ខ្លួនដែលថា ចិរវេលានៃអាជ្ញាយុកាលចំពោះបទឧក្រិដ្ឋតាមច្បាប់ជាតិមិនទាន់ផុតរលត់នៅឡើយ មុនពេលចិរវេលានៃអាជ្ញាយុកាលត្រូវបានពន្យារនៅឆ្នាំ ២០០១ តាមរយៈច្បាប់ស្ដីពី

---

[៨] សំណុំរឿង ០០១/១៨-០៧-២០០៧-អវតក/អជសង *កាំង ហ្គេកអ៊ាវ ហៅ ឌុច* សេចក្ដីសម្រេចស្ដីពីអញ្ញត្រកម្មទាក់ទងនឹងចិរវេលានៃអាជ្ញាយុកាលចំពោះបទល្មើសជាតិដែលលើកឡើងដោយមេធាវីការពារក្ដី ឯកសារ E187 ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១០ កថាខណ្ឌ ៥៦។

[៩] ដីកាដំណោះស្រាយ ឯកសារ D427 ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០១០ កថាខណ្ឌ ១៦១៣។ ដោយគ្មានការវិភាគ ដីកាដំណោះស្រាយពណ៌នាអំពីបទល្មើសនានាដែលមាននៅក្នុងមាត្រា ២០៩ និង ២១០ នៃក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦ ថាជា "ការធ្វើវាយប្រហារលើសាសនា"។ ក្រៅពីបទល្មើសដែលមានចេតនាជាក់លាក់ ផ្ទុយទៅវិញ មាត្រា ២០៩ និង ២១០ ទុកជាបទឧក្រិដ្ឋនូវ "ការប៉ុនប៉ងលើអាយុជីវិត (ឬការប៉ុនប៉ងលើជនដែលស្ថិតនៅក្នុងករណីនៃមាត្រា ២១០) ចំពោះការគោរពសាសនាដែលត្រូវបានទទួលស្គាល់ដោយរដ្ឋាភិបាលកម្ពុជា ឬនៅក្នុងប្រតិបត្តិការទាក់ទងនឹងការអនុវត្តមុខងារក្រសួងរបស់ខ្លួន"។

[១០] *សូមមើល* សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ ឯកសារ D427/1/26 ចុះថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១១។ សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ និង នួន ជា ប្រឆាំងនឹងដីកាដំណោះស្រាយ ឯកសារ D427/2/12 ចុះថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១១។ សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់ ខៀវ សំផន ប្រឆាំងនឹងដីកា ដំណោះស្រាយ ឯកសារ D427/4/14 ចុះថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១១។ អង្គបុរេជំនុំជម្រះបានចេញជាបន្តបន្ទាប់នូវសំអាងហេតុពាក់ព័ន្ធនឹងបណ្ដឹងឧទ្ធរណ៍របស់ ខៀវ សំផន នៅថ្ងៃទី ២១ ខែ មករា ឆ្នាំ ២០១១, បណ្ដឹងឧទ្ធរណ៍របស់ នួន ជា និង អៀង ធីរិទ្ធ នៅថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០១១ និងពាក់ព័ន្ធនឹងបណ្ដឹងឧទ្ធរណ៍របស់ អៀង សារី នៅថ្ងៃទី ១១ ខែ មេសា ឆ្នាំ ២០១១ ("សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់ ខៀវ សំផន ប្រឆាំងនឹងដីកាដំណោះស្រាយ" ឯកសារ D427/4/15 ចុះថ្ងៃទី ២១ ខែ មករា ឆ្នាំ ២០១១។ "សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់ នួន ជា និង អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ" ឯកសារ D427/3/15 ចុះថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០១១ និង "សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ" ឯកសារ D427/1/30 ចុះថ្ងៃទី ១១ ខែ មេសា ឆ្នាំ ២០១១)។

ការបង្កើត អ.វ.ត.ក [១១]។ ការិយាល័យសហព្រះរាជអាជ្ញាបានដាក់សេចក្ដីសន្និដ្ឋានរបស់ខ្លួននៅថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០១១[១២]។ នៅថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០១១ ចម្លើយតបនានាត្រូវបានដាក់ដោយមេធាវីការពារក្ដី ខៀវ សំផន ដោយមានការចូលរួមដោយក្រុមមេធាវីការពារក្ដី អៀង សារី, អៀង ធីរិទ្ធ និង នួន ជា[១៣]។ ភាគីនានាត្រូវបានផ្ដល់ឱកាសឲ្យធ្វើសេចក្ដីសន្និដ្ឋានផ្ទាល់មាត់ស្ដីពីបញ្ហានេះនៅក្នុងពេលសវនាការបឋម[១៤]។

## ៣. សារណា

### *៣.១. អញ្ញត្រកម្មបានផ្អែកលើវិការៈដែលត្រូវបានចោទប្រកាន់ថាមាននៅក្នុងផ្នែកខ្លះនៃដីកាដំណោះស្រាយពាក់ព័ន្ធនឹងបទឧក្រិដ្ឋតាមច្បាប់ជាតិ*

៥. ញត្តិរបស់ អៀង សារី ស្នើសុំលុបចោលផ្នែកខ្លះនៃដីកាដំណោះស្រាយ លើកឡើងថា ដីកាដំណោះស្រាយមិនបានបញ្ជាក់ពីអង្គហេតុនានាដែលសហចៅក្រមស៊ើបអង្កេតពិចារណាឃើញថា គាំទ្រដល់ការចោទប្រកាន់ស្របតាមមាត្រា ៣(ថ្មី) ចំពោះបទឧក្រិដ្ឋតាមច្បាប់ជាតិនៃការធ្វើមនុស្សឃាត ការធ្វើទារុណកម្ម និងការវាយប្រហារលើសាសនា ឬទម្រង់នៃការទទួលខុសត្រូវដែលជនជាប់ចោទអាចត្រូវបានរកឃើញថា ត្រូវទទួលខុសត្រូវចំពោះបទឧក្រិដ្ឋទាំងនេះនោះទេ។ ជាលទ្ធផល ផ្នែកខ្លះនៃដីកាដំណោះស្រាយដែលសំដៅលើបទឧក្រិដ្ឋដែលស្ថិតនៅក្រោមមាត្រា ៣ (ថ្មី) ខកខានមិនបានជូនដំណឹងឲ្យបានគ្រប់គ្រាន់ដល់ជនជាប់ចោទអំពីការចោទប្រកាន់មកលើខ្លួន។ ហេតុដូច្នេះ ផ្នែកទាំងនេះនៃដីកាដំណោះស្រាយត្រូវចាត់ទុកជាមោឃៈដោយសារមានវិការៈផ្នែកនីតិវិធី[១៥]។

---

[១១] "សេចក្ដីណែនាំដល់ភាគីពាក់ព័ន្ធនឹងអញ្ញត្រកម្ម និងបញ្ហាពាក់ព័ន្ធ" ឯកសារ E51/7 ចុះថ្ងៃទី ០៥ ខែ មេសា ឆ្នាំ ២០១១។

[១២] "សេចក្ដីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញាស្ដីពីអាជ្ញាយុកាលចំពោះបទល្មើសជាតិ" ឯកសារ E51/7/1 ចុះថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០១១ ("សេចក្ដីសន្និដ្ឋានបន្ថែមរបស់សហព្រះរាជអាជ្ញា")។

[១៣] "ចម្លើយតបរួមរបស់ អៀង សារី អៀង ធីរិទ្ធ និង នួន ជា ទៅនឹងសេចក្ដីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញាស្ដីពីអាជ្ញាយុកាលចំពោះបទល្មើសជាតិ" ឯកសារ E51/7/3 ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០១១ ("ចម្លើយតបរួមរបស់មេធាវីការពារក្ដី")។ "ចម្លើយទៅនឹងសេចក្ដីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញាទាក់ទិននឹងអាជ្ញាយុកាលនៃបទឧក្រិដ្ឋនៅក្នុងច្បាប់ជាតិ" ឯកសារ E51/7/2 ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០១១ ("ចម្លើយតបទៅនឹង ខៀវ សំផន")។

[១៤] "របៀបវារៈសម្រាប់សវនាការបឋម" ឯកសារ E86/1 ចុះថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ២០១១។ ប្រតិចារឹក ចុះថ្ងៃទី ២៩ ខែ មិថុនា ឆ្នាំ ២០១១ (សវនាការបឋម) ឯកសារ E1/6.1 ទំព័រ ១៨ ដល់ ៩១។

[១៥] "ញត្តិរបស់ អៀង សារី ស្នើសុំលុបចោលផ្នែកខ្លះនៃដីកាដំណោះស្រាយ" កថាខណ្ឌ ៣ ដល់ ៦។

៦. ការិយាល័យសហព្រះរាជអាជ្ញាជំទាស់ទៅនឹងញត្តិនេះ ដោយហេតុថា ក្របខ័ណ្ឌច្បាប់របស់ អ.វ.ត.ក មិនបានចែងអំពីការដាក់ញត្តិស្នើសុំធ្វើការកែប្រែ ឬសុំលុបចោលផ្នែកខ្លះនៃដីកាដំណោះស្រាយនៅដំណាក់កាលជំនុំជម្រះនោះទេ ហើយថា ញត្តិនេះបានលើកឡើងផ្ទុយពីច្បាប់ជាធរមានពាក់ព័ន្ធនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ និងផ្ទុយពីសំអាងហេតុនានានៅក្នុងដីកានេះផងដែរ។ ដោយយោងទៅលើភាពត្រួតគ្នាជាសំខាន់រវាងបទឧក្រិដ្ឋតាមច្បាប់ជាតិដែលត្រូវបានចោទប្រកាន់ និងបទឧក្រិដ្ឋ មួយចំនួនដែលបង្កើតបានជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនៅក្នុងដីកាដំណោះស្រាយនោះ សហព្រះរាជអាជ្ញាយល់ថា ដីកានេះបានរួមបញ្ចូលនូវអង្គហេតុទាំងឡាយដែលមានលក្ខណៈ ពិសេសគ្រប់គ្រាន់សម្រាប់ការជំនុំជម្រះ។ ពុំមានការហាមឃាត់មិនឱ្យមានការចោទប្រកាន់បទឧក្រិដ្ឋក្នុងទម្រង់ផ្សេងគ្នា ឬត្រួតគ្នាផ្អែកលើអង្គហេតុតែមួយឡើយ។ ដោយហេតុថាទម្រង់នៃការទទួលខុសត្រូវនៃបទឧក្រិដ្ឋតាមច្បាប់ជាតិមានលក្ខណៈស្រដៀងគ្នាទៅនឹងទម្រង់នៃការទទួលខុសត្រូវនៃបទឧក្រិដ្ឋអន្តរជាតិដូចបានគូសបញ្ជាក់រួចហើយនៅក្នុងដីកាដំណោះស្រាយនោះ វាមិនមានការប៉ះពាល់ដល់ជនជាប់ចោទ ដោយសារតែការមិនបានកំណត់ឱ្យបានលម្អិតអំពីអង្គហេតុជាក់លាក់នោះទេ[១៦]។

### *៣.១.១ អញ្ញត្រកម្មនានារបស់មេធាវីការពារក្តីដែលជំទាស់នឹងនីត្យានុកូលភាពនៃមាត្រា ៣ (ថ្មី) នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក (បទឧក្រិដ្ឋតាមច្បាប់ជាតិ)*

៧. ជនជាប់ចោទទាំងអស់អះអាងថា មាត្រា ៣ (ថ្មី) នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក រំលោភលើគោលការណ៍នីត្យានុកូលភាព និងភាពអប្រតិសកម្មនៃច្បាប់[១៧]។ មេធាវីការពារក្តី អៀង សារី អៀង ធីរិទ្ធ និង ខៀវ សំផន លើកឡើងថែមទៀតថា មាត្រា ៣ (ថ្មី) នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក រំលោភលើសិទ្ធិស្មើភាពគ្នាចំពោះមុខច្បាប់របស់ជនជាប់ចោទ ពីព្រោះតែការពន្យារ

---

[១៦] "ចម្លើយតបរបស់ សហព្រះរាជអាជ្ញាទៅនឹងញត្តិរបស់ អៀង សារី ស្នើសុំលុបចោលផ្នែកខ្លះនៃដីកាដំណោះស្រាយ" កថាខណ្ឌ ១ ដល់ ៧, ១៣ និង ១៨ ដល់១៩។

[១៧] អញ្ញត្រកម្មរបស់ អៀង ធីរិទ្ធ កថាខណ្ឌ ២២ ដល់ ២៣។ អញ្ញត្រកម្មរបស់ នួន ជា កថាខណ្ឌ ៤១។ អញ្ញត្រកម្មរបស់ ខៀវ សំផន កថាខណ្ឌ ១០ និង ២៣ ព្រមទាំង អញ្ញត្រកម្មរបស់ អៀង សារី កថាខណ្ឌ ២៨យ (ដែលបានបញ្ចូលតាមរយៈការយោង "សារណាឆ្លើយតបទៅនឹងចម្លើយតបរួមរបស់សហព្រះរាជអាជ្ញាទៅនឹងបណ្តឹងឧទ្ធរណ៍របស់ នួន ជា អៀង សារី និង អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ" ឯកសារ D427/1/23 ចុះថ្ងៃទី ០៦ ខែ ធ្នូ ឆ្នាំ ២០១០ កថាខណ្ឌ ៤២ ដល់ ៤៥)។

ចិរវេលាអាជ្ញាយុកាល ត្រូវបានអនុវត្តចំពោះតែការចោទប្រកាន់នៅចំពោះមុខ អ.វ.ត.ក ប៉ុណ្ណោះ និងមិនអនុវត្តចំពោះមុខតុលាការកម្ពុជាផ្សេងៗទៀតនោះ[១៨]។

៨. ការិយាល័យសហព្រះរាជអាជ្ញាលើកឡើងថា មាត្រា ៣ (ថ្មី) នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក មិនរំលោភលើគោលការណ៍នីត្យានុកូលភាពទេ ពីព្រោះមាត្រា ១៥ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ គ្រាន់តែហាមមិនឱ្យមានការផ្តន្ទាទោសចំពោះអំពើដែលមិនទាន់បង្កើតបានជាបទល្មើសមួយ នៅពេលអំពើនោះត្រូវបានប្រព្រឹត្តតែប៉ុណ្ណោះ។ ជនជាប់ចោទត្រូវបានចោទប្រកាន់ពីបទឧក្រិដ្ឋតាមក្រមព្រហ្មទណ្ឌ ឆ្នាំ ១៩៥៦ ដែលអំពើឧក្រិដ្ឋទាំងនោះត្រូវផ្តន្ទាទោស នៅចន្លោះឆ្នាំ ១៩៧៥ និងឆ្នាំ ១៩៧៩។ ក្រុមប្រឹក្សាធម្មនុញ្ញកម្ពុជាកាលពីមុនបានលើកឡើងផងដែរ ថា មាត្រា ៣ (ថ្មី) គឺស្របនឹងច្បាប់រដ្ឋធម្មនុញ្ញ និងស្របតាមកាតព្វកិច្ចអន្តរជាតិរបស់ប្រទេស កម្ពុជា។ លើសពីនេះទៀត សិទ្ធិស្មើភាពគ្នាចំពោះមុខច្បាប់របស់ជនជាប់ចោទមិនត្រូវបានរំលោភ បំពាននោះទេ។ ដូចដែលគណៈកម្មាធិការសិទ្ធិមនុស្សបានអះអាងរួចហើយថា ការជំនុំជម្រះក្តីនៅ ចំពោះមុខតុលាការវិសាមញ្ញនានា ដែលអនុវត្តនីតិវិធីខុសគ្នាពីតុលាការសាមញ្ញ មិនបំពានលើ កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយឡើយ ដោយហេតុថា ការជ្រើសយក ជនទាំងឡាយទៅកាត់សេចក្តីនៅចំពោះមុខតុលាការទាំងនោះ គឺត្រូវបានធ្វើឡើងដោយផ្អែកលើ លក្ខណៈវិនិច្ឆ័យដែលមានហេតុផលសមស្រប និងជាសត្យានុម័ត[១៩]។

*៣.១.២ សារណាបន្ថែមរបស់ការិយាល័យសហព្រះរាជអាជ្ញាពាក់ព័ន្ធនឹងការព្យួរចិរវេលាអាជ្ញាយុកាល*

៩. ការិយាល័យសហព្រះរាជអាជ្ញាលើកឡើងថា ចិរវេលាអាជ្ញាយុកាលត្រូវបានព្យួរយ៉ាងហោចណាស់រហូតដល់ឆ្នាំ ១៩៩៣ ពីព្រោះការអនុវត្តនៅកម្រិតជាតិ និងអន្តរជាតិ បង្ហាញថា ស្ថានភាពនៃសង្គ្រាមដែលបង្អាក់ដំណើរការតុលាការតម្រូវឱ្យមានការព្យួរអាជ្ញាយុកាល។ វាជាការជាក់ស្តែង

[១៨] អញ្ញត្រកម្មរបស់ អៀង សារី កថាខណ្ឌ ២៨គ និង ឃ (ដែលបានបញ្ចូលតាមរយៈការយោងបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ ឯកសារ D427/1/6 ចុះថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០១១ កថាខណ្ឌ ១៥៤ ដល់ ១៥៧ និង "សារណាឆ្លើយតបទៅនឹងចម្លើយតបរួមរបស់សហព្រះរាជអាជ្ញាទៅនឹងបណ្តឹងឧទ្ធរណ៍របស់ នួន ជា, អៀង សារី និង អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ" ឯកសារ D427/1/23 ចុះថ្ងៃទី ០៦ ខែ ធ្នូ ឆ្នាំ ២០១០ កថាខណ្ឌ ៦១ ដល់ ៦៣)។ អញ្ញត្រកម្មរបស់ ខៀវ សំផន កថាខណ្ឌ ៩ និង អញ្ញត្រកម្មរបស់ អៀង ធីរិទ្ធ កថាខណ្ឌ ២៣។

[១៩] ចម្លើយតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ១៣ និង ១៥។ ប្រតិចារឹក ចុះថ្ងៃទី ២៩ ខែ មិថុនា ឆ្នាំ ២០១១ (សវនាការបឋម) ឯកសារ E1/6.1 ទំព័រ ៤០ ដល់ ៤១។

ដែលថា គេពុំអាចដំណើរការចោទប្រកាន់លើជនជាប់ចោទបានទេ ដោយសារតែប្រព័ន្ធតុលាការនៅក្នុងប្រទេសកម្ពុជាមិនដំណើរការ និងដោយសារតែនៅមានជម្លោះប្រដាប់អាវុធនៅ ចន្លោះឆ្នាំ ១៩៧៩ និងឆ្នាំ ១៩៩៩។ លើសពីនេះទៀត ដោយសារថា ជនជាប់ចោទត្រូវបានចោទប្រកាន់ឱ្យទទួលខុសត្រូវមួយផ្នែក ចំពោះការធ្វើឱ្យចុះខ្សោយនៃប្រព័ន្ធតុលាការនៅក្នុងអំឡុងពេលនោះ ដូច្នេះជនជាប់ចោទមិនត្រូវបានអនុញ្ញាតឱ្យទទួលផលប្រយោជន៍ពីពេលវេលាដែលកន្លងផុតទៅ ឬពីកាលៈទេសៈដែលបានរារាំងមិនឱ្យមានការចោទប្រកាន់ពួកគេកាលពីពេលមុននោះបានទេ[២០]។

១០. មេធាវីការពារក្ដីបានតវ៉ាថា ថិរវេលាអាជ្ញាយុកាលដែលបានកំណត់នៅក្នុងមាត្រា ១០៩ នៃក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦ បានផុតរលត់នៅឆ្នាំ ១៩៨៩ មុនពេលមានការពន្យារថិរវេលាអាជ្ញាយុកាលនៅឆ្នាំ ២០០១ តាមរយៈមាត្រា ៣ (ថ្មី) នៃច្បាប់ស្ដីពីការបង្កើត អ.វ.ត.ក។ អង្គនីតិប្បញ្ញត្តិកម្ពុជាពុំបានអនុម័តបទប្បញ្ញត្តិណាមួយដែលកំណត់ថាថិរវេលាអាជ្ញាយុកាលត្រូវបានព្យួរនោះឡើយ[២១]។ លើសពីនេះទៀត ទោះបីជាមានភាពទន់ខ្សោយផ្នែកប្រព័ន្ធច្បាប់កម្ពុជាក្រោយឆ្នាំ ១៩៧៩ ក៏ដោយ ក៏ប្រព័ន្ធតុលាការកម្ពុជាបានដំណើរការគ្រប់គ្រាន់ក្នុងការធ្វើការចោទប្រកាន់លើជន-ជាប់ចោទ ដែលអាចធ្វើបានក្នុងរយៈពេល ១០ឆ្នាំ បន្ទាប់ពីឆ្នាំ ១៩៧៩។ មានរឿងក្ដីជាច្រើនដែលអំពើឧក្រិដ្ឋមានលក្ខណៈស្រដៀងគ្នាទៅនឹងរឿងក្ដីនៅចំពោះមុខនេះ ត្រូវបានចោទប្រកាន់ និង ជំនុំ-ជម្រះនៅក្នុងប្រទេសកម្ពុជានៅចន្លោះឆ្នាំ ១៩៧៩ និងឆ្នាំ ១៩៩៣[២២]។

## ៤. សម្អាងហេតុ

### *៤.១. ការវាយតម្លៃលើបទឧក្រិដ្ឋតាមច្បាប់ជាតិដូចដែលបានបញ្ចូលនៅក្នុងដីកាដំណោះស្រាយ*

១១. ដីកាដំណោះស្រាយបង្ហាញថា សហចៅក្រមស៊ើបអង្កេតមិនអាចឯកភាពលើខ្លឹមសាររួមស្ដីពីបញ្ហាអាជ្ញាយុកាលសម្រាប់បទឧក្រិដ្ឋតាមច្បាប់ជាតិនានាដែលពាក់ព័ន្ធបានទេ។ ដើម្បីជៀសវាងមិនចាំបាច់ឱ្យមានការប្រើប្រាស់នីតិវិធីដើម្បីដោះស្រាយការខ្វែងយោបល់គ្នា ដោយអនុលោមតាមវិធាន ៧២ នៃវិធានផ្ទៃក្នុងដែលអាចនាំឱ្យមានការពន្យារកិច្ចដំណើរការនីតិវិធី សហចៅក្រមស៊ើបអង្កេត

---

[២០] ប្រតិចារឹក ចុះថ្ងៃទី ២៩ ខែ មិថុនា ឆ្នាំ ២០១១ (សវនាការបឋម) ឯកសារ E1/6.1 ទំព័រ ៣៣ ដល់ ៤០ និង ៥០ ដល់ ៥៧។ សូមមើលផងដែរ ចម្លើយតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ១៣, ១៦, ២៧ ដល់ ៣៣។

[២១] អញ្ញត្រកម្មរបស់ អៀង សារី កថាខណ្ឌ ២៨យ (ដែលបានបញ្ចូលតាមរយៈការយោង "សារណាឆ្លើយតបទៅនឹងចម្លើយតបរួមរបស់សហព្រះរាជអាជ្ញាទៅនឹងបណ្ដឹងឧទ្ធរណ៍របស់ នួន ជា, អៀង សារី និង អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ" ឯកសារ D427/1/23 ចុះថ្ងៃទី ០៦ ខែ ធ្នូ ឆ្នាំ ២០១០ កថាខណ្ឌ ៥៣ ដល់ ៥៤)។ អញ្ញត្រកម្មរបស់ នួន ជា កថាខណ្ឌ ៤១។

[២២] "ចម្លើយតបរួមរបស់មេធាវីការពារក្ដី" កថាខណ្ឌ ៣ ដល់ ២៥។ ចម្លើយតបរបស់ ខៀវ សំផន កថាខណ្ឌ ៥ ដល់ ៧។

បានសម្រេច "ឯកភាពទទួលយកសេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញា [ដែលស្នើឱ្យបញ្ជូនជនជាប់ចោទទៅធ្វើការជំនុំជម្រះក្តី ដោយផ្អែកលើបទឧក្រិដ្ឋនានា ដែលមាននៅក្នុងក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦] ដោយទុកលទ្ធភាពឱ្យអង្គជំនុំជម្រះសាលាដំបូងធ្វើការវាយតម្លៃអំពីចំណាត់ការបន្តនៃនីតិវិធីដែលពាក់ព័ន្ធនឹងបទឧក្រិដ្ឋទាំងអស់នេះ..."[២៣]។

១២. នៅក្នុងសាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ អង្គបុរេជំនុំជម្រះបានលើកឡើងថា អង្គហេតុ និងទម្រង់នានានៃការទទួលខុសត្រូវដែលបានលើកឡើងនៅក្នុងផ្នែកផ្សេងៗនៃដីកាដំណោះស្រាយនៅក្នុងសំណុំរឿង ០០២ ជាទូទៅអាចត្រូវបានកំណត់លក្ខណៈថាជាបទចោទនៃការធ្វើមនុស្សឃាត ការធ្វើទារុណកម្ម និងការវាយប្រហារលើសាសនាស្របតាមក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦ ផងដែរ។ ហេតុដូច្នេះ អង្គបុរេជំនុំជម្រះបានពិចារណាឃើញថា ពុំមានឧបសគ្គក្នុងការបញ្ជូនជនជាប់ចោទទៅធ្វើការជំនុំជម្រះក្តីដោយផ្អែកលើបទឧក្រិដ្ឋតាមច្បាប់ជាតិនានាឡើយ[២៤]។ ប៉ុន្តែ អង្គបុរេជំនុំជម្រះបានកត់សម្គាល់ឃើញថា បញ្ហាថាតើអង្គហេតុនានានៅក្នុងដីកាដំណោះស្រាយ ពិតជាអាចកំណត់បានថាជាការធ្វើមនុស្សឃាត ការធ្វើ

---

[២៣] ដីកាដំណោះស្រាយ ឯកសារ D427 ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០១០ កថាខណ្ឌ ១៥៧៤។ *សូមមើលផងដែរ* កថាខណ្ឌ ១៥៦៨ ដល់ ១៥៧២ (ដោយកត់សម្គាល់ពីការខកខានរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងការព្រមព្រៀងគ្នានៅក្នុងសំណុំរឿង ០០១ លើបញ្ហាថាតើរយៈពេលអាជ្ញាយុកាលត្រូវបានផ្អាក ឬត្រូវបានពន្យារនៅចន្លោះឆ្នាំ ១៩៧៩ និង ១៩៩៣ និងនៅពេលដែលមិនមានសំឡេងគាំទ្រភាគច្រើន អង្គជំនុំជម្រះសាលាដំបូងមិនអាចពិចារណាពីពិរុទ្ធភាព ឬភាពគ្មានពិរុទ្ធរបស់ជនជាប់ចោទពាក់ព័ន្ធនឹងបទឧក្រិដ្ឋជាតិ)។ សូមមើលបន្ថែមទៀត អញ្ញត្រកម្មរបស់ អៀង សារី កថាខណ្ឌ ២៨ គ (ដោយបានរួមបញ្ចូលតាមរយៈការយោងបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ ឯកសារ D427/1/6 ចុះថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០១០ កថាខណ្ឌ ១៧៥ ដោយលើកឡើងថា នៅពេលដែលសហចៅក្រមស៊ើបអង្កេត មិនឯកភាពនៅក្នុងដីកាដំណោះស្រាយអំពីការអនុវត្តបទឧក្រិដ្ឋជាតិ ការចោទប្រកាន់ត្រូវបានហាមឃាត់ រីឯយន្តការដែលមាន ចែងនៅក្នុងវិធានផ្ទៃក្នុង ៧២ ត្រូវយកមកប្រើប្រាស់)។ អង្គបុរេជំនុំជម្រះបានសម្រេចតាំងពីពេលនោះមកថា យន្តការដែលមាននៅក្នុងវិធានផ្ទៃក្នុង ៧២ មិនមែនជាយន្តការចាំបាច់នោះទេ។ នៅពេលដែលអង្គបុរេជំនុំជម្រះមិនបានទទួលនូវវិវាទណាមួយទេនោះ គឺថាការស៊ើបសួរត្រូវតែបន្ត (សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ ឯកសារ D427/1/30 ចុះថ្ងៃទី ១១ ខែ មេសា ឆ្នាំ ២០១១ កថាខណ្ឌ ២៧៤)។

[២៤] សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ ឯកសារ D427/1/30 ចុះថ្ងៃទី ១១ ខែ មេសា ឆ្នាំ ២០១១ កថាខណ្ឌ ២៩៦ (ដោយលើកលែងទម្រង់នៃការទទួលខុសត្រូវដែលសហចៅក្រមស៊ើបអង្កេតបានលើកឡើងថាមានការពាក់ព័ន្ធទៅនឹងបទឧក្រិដ្ឋអន្តរជាតិប៉ុណ្ណោះ)។

ទារុណកម្ម ឬការវាយប្រហារលើសាសនា ស្របតាមក្រមព្រហ្មទណ្ឌ ឆ្នាំ ១៩៥៦ ឬយ៉ាងណានោះ គឺជាបញ្ហាដែលអង្គជំនុំជម្រះសាលាដំបូងជាអ្នកសម្រេច[២៥]។

១៣. ផ្នែកសេចក្ដីសម្រេចបញ្ចប់នៃដីកាដំណោះស្រាយ បានចោទប្រកាន់ជនជាប់ចោទទាំងអស់ពីបទរំលោភលើក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦ ដូចជាអំពើមនុស្សឃាត, ការធ្វើទារុណកម្ម និងការវាយប្រហារលើសាសនា ដោយអនុលោមតាមមាត្រា ៣, មាត្រា ២៩ និង មាត្រា ៣៩ (ថ្មី) នៃច្បាប់ស្ដីពីការបង្កើត អ.វ.ត.ក និងមាត្រា ២០៩, មាត្រា ២១០, មាត្រា ៥០០, មាត្រា ៥០១, មាត្រា ៥០៣ និង (ឬ)[២៦] មាត្រា ៥០៨ នៃក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦[២៧]។

១៤. ត្រង់ផ្នែកពាក់ព័ន្ធនានានៃដីកាដំណោះស្រាយមិនបានបញ្ជាក់ឱ្យបានច្បាស់លាស់នូវអង្គច្បាប់ ឬធាតុផ្សំនៃបទឧក្រិដ្ឋតាមច្បាប់ជាតិឡើយ[២៨] ហើយក៏ពុំបានបញ្ជាក់អំពីមូលដ្ឋានអង្គហេតុនៃការចោទ

---

[២៥] សាលដីកាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ ឯកសារ D427/1/30 ចុះថ្ងៃទី ១១ ខែ មេសា ឆ្នាំ ២០១១ កថាខណ្ឌ ២៩៦។

[26] ដីកាដំណោះស្រាយក្នុងសំណៅជាភាសាអង់គ្លេសខុសពីសំណៅជាភាសាខ្មែរ និងភាសាបារាំង ត្រង់បទល្មើសដែលបានដាក់បញ្ចូលនៅក្នុងផ្នែកសេចក្ដីសម្រេចបញ្ចប់។ កថាខណ្ឌ ១៦១៣ នៃសំណៅជាភាសាអង់គ្លេសបានចោទប្រកាន់ជនជាប់ចោទពីបទល្មើសនានាដែលមានរៀបរាប់ក្នុង "...មាត្រា ៥០៣ និង មាត្រា ៥០៨"។ ចំណែកសំណៅជាភាសាខ្មែរ និងភាសាបារាំង ចង់និយាយសំដៅដល់បទល្មើសទាំងឡាយដែលមានចែងក្នុង "...មាត្រា ៥០៣ ដល់មាត្រា ៥០៨" នៃក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦ ទៅវិញ (ដីកាដំណោះស្រាយ, លេខឯកសារ D427, ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០១០ កថាខណ្ឌ ១៦១៣), *សូមមើលផងដែរ* កថាខណ្ឌ ១៥៧៥ (ដែលបានកត់សម្គាល់ឃើញនូវចំណុចខុសគ្នាស្រដៀងនេះនៅក្នុងដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញាពាក់ព័ន្ធនឹងការចោទប្រកាន់អំពីការវាយប្រហារលើសាសនា ប៉ុន្តែបានសន្និដ្ឋានដោយពុំពន្យល់ថា "ជាការពុំចាំបាច់ដែលត្រូវបែងចែកចំណុចខុសគ្នារវាងបទល្មើសទាំងបីគឺ [ការវាយប្រហារលើសាសនា ការធ្វើមនុស្សឃាត និងការធ្វើទារុណកម្ម])"។

[២៧] *សូមមើល* ដីកាដំណោះស្រាយ, ឯកសារ D427, ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០១០, កថាខណ្ឌ ១៦១៣ (ផ្នែកទីប្រាំ៖ សេចក្ដីសម្រេចបញ្ចប់)។

[២៨] បទល្មើសនានាក្រោមក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦ ដែលដីកាដំណោះស្រាយបានលើកឡើង រួមបញ្ចូលនូវបទល្មើសជាច្រើនដែលមានធាតុផ្សំខុសៗគ្នា។ *សូមមើល ឧទាហរណ៍* មាត្រា ៥០៣ ("កាលបើមនុស្សឃាតបណ្ដាលមកពីអំពើដែលប្រព្រឹត្តដោយចេតនាត្រឹមតែចង់ឱ្យឈឺរូបកាយបុគ្គលណាម្នាក់ប៉ុណ្ណោះទេមិនចង់ឱ្យបុគ្គលនោះស្លាប់ទេ ប៉ុន្តែអំពើនោះបណ្ដាលឱ្យស្លាប់បុគ្គលនោះទៅវិញ មនុស្សឃាតនេះត្រូវទុកជាបទមនុស្សឃាតគ្មានមរណចេតនាទេ")។ មាត្រា ៥០៤ ("កាលបើមនុស្សឃាតបណ្ដាលមក ឬអាចបណ្ដាលមកពីចិត្តដែលស្ទុះឡើងភ្លាមៗចង់ឱ្យស្លាប់ មនុស្សឃាតនេះឱ្យឈ្មោះថាឃាតកម្ម ឬបំណងឃាតកម្ម"), មាត្រា ៥០៥ ("ចៅក្រមអាចសន្និដ្ឋានថាឃាតករមានមរណចេតនាបានកាលណាបើឃាតករបានប្រើសស្ត្រាវុធគួរដល់ស្លាប់", មាត្រា ៥០៦ ("កាលណាបើមនុស្សឃាតបណ្ដាលមក ឬអាចបណ្ដាលមកពីអំពើដោយចេតនា ឬពីបំណងដោយចេតនា ហើយចេតនានោះបានសម្រេចដាច់ខាតជាមុនផង មនុស្សឃាតនេះឱ្យឈ្មោះថា ហានកម្ម ឬបំណងនៃហានកម្ម") ហើយមាត្រា ៥០៧ ("កាល

ប្រកាន់ទាំងនេះ ឬយោងទៅលើផ្នែកណាមួយផ្សេងនៃដីកាដំណោះស្រាយដែលមានរៀបរាប់អំពីអង្គហេតុសំខាន់ពាក់ព័ន្ធនឹងបទឧក្រិដ្ឋស្រដៀងនេះដែរ។ ក្រៅពីពុំបានបញ្ជាក់ឱ្យបានច្បាស់លាស់ថា បទឧក្រិដ្ឋតាមច្បាប់ជាតិទាំងនេះគ្រាន់តែជាមែកធាងនៃបទឧក្រិដ្ឋស្រដៀងគ្នាតាមច្បាប់អន្តរជាតិ (ពិសេស ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិក្នុងប្រភេទជាបទមនុស្សឃាត, ការធ្វើទារុណកម្ម, និងការធ្វើទុក្ខបុកម្នេញ) ដីកាដំណោះស្រាយបានយោងទៅលើសំអាងហេតុរបស់អង្គបុរេជំនុំជម្រះដែលថា បទឧក្រិដ្ឋនានាតាមច្បាប់ជាតិ "មិនអាចដាក់បញ្ចូលទៅក្រោមបទឧក្រិដ្ឋនានាតាមច្បាប់អន្តរជាតិបានទេនៅក្នុងដីកាដំណោះស្រាយនេះ ពីព្រោះបទឧក្រិដ្ឋនីមួយៗតាមច្បាប់ជាតិគឺតម្រូវឱ្យមានធាតុផ្សំជាក់ស្ដែងដែលធាតុផ្សំនេះមិនមាននៅក្នុងបទឧក្រិដ្ឋតាមច្បាប់អន្តរជាតិ ឬក៏ធាតុផ្សំនៃឧក្រិដ្ឋតាមច្បាប់អន្តរជាតិមាននៅក្នុងបទឧក្រិដ្ឋជាតិនោះឡើយ"[២៩]។ ជាងនេះទៅទៀត ស.ច.ស ខ្លួនឯង មិនសម្រេចឱ្យបានសមស្របបំផុតចំពោះបទឧក្រិដ្ឋទាំងនេះនោះទេ បែរជាទុកបញ្ហានេះឱ្យអង្គជំនុំជម្រះសាលាដំបូងជាអ្នកសម្រេចថា តើត្រូវធ្វើចំណាត់ការនីតិវិធីពាក់ព័ន្ធនឹងបទឧក្រិដ្ឋទាំងនេះយ៉ាងណានោះទៅវិញ[៣០]។

១៥. អង្គជំនុំជម្រះសាលាដំបូងសង្កេតឃើញថា ដីកាដំណោះស្រាយត្រង់ផ្នែកនានាពាក់ព័ន្ធនឹងបទឧក្រិដ្ឋតាមច្បាប់ជាតិមិនបានរៀបរាប់អំពីអង្គហេតុពាក់ព័ន្ធសំខាន់ៗ ដែលនាំទៅដល់ការចោទប្រកាន់ទាំងអស់នោះឡើយ ហើយក៏មិនបានបង្ហាញប្រភេទនៃការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ជនជាប់ចោទដែលត្រូវបានចោទប្រកាន់ពាក់ព័ន្ធនឹងបទឧក្រិដ្ឋទាំងអស់នោះទៀតផង។ ហេតុដូច្នេះ អង្គជំនុំជម្រះមិនអាចកំណត់ប្រភេទបទឧក្រិដ្ឋជាក់ស្ដែងដែលបានចោទមកលើជនជាប់ចោទ ឬទម្រង់នៃការទទួលខុសត្រូវដែលអាចយកមកអនុវត្តចំពោះជនជាប់ចោទបានឡើយ។ បើទោះបីមានការសន្និដ្ឋានច្បាស់លាស់ថា សហឧក្រិដ្ឋកម្មរួមគឺជាទម្រង់មួយនៃការទទួលខុសត្រូវដែលអាចយកមកអនុវត្តបានចំពោះតែបទឧក្រិដ្ឋតាមច្បាប់អន្តរជាតិក្ដី ក៏ទម្រង់មួយនេះត្រូវបានដាក់បញ្ចូលទៅក្នុង

---

ណាបើមនុស្សឃាតបណ្ដាលមក ឬអាចបណ្ដាលមកពីវត្ថុមានជាតិពុលដល់ស្លាប់ដែលជនណាម្នាក់ដាក់ដោយចេតនាចង់បំពុលមែន មនុស្សឃាតនេះឱ្យឈ្មោះថាបទបំពុល ឬបំណងក្នុងបទបំពុល")។

[២៩] ដីកាដំណោះស្រាយ, ឯកសារ D427, ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០១០, កថាខណ្ឌ ១៥៦៥ (ដោយបានយោងទៅលើ "បណ្ដឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជំទាស់ទៅនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ចុះថ្ងៃទី ០៨ ខែ សីហា ឆ្នាំ ២០០៨ លើករណីរបស់កាំង ហ្កេកអ៊ាវ ហៅ "ឌុច", ឯកសារ D99/3/3, ចុះថ្ងៃទី ០៦ ខែ សីហា ឆ្នាំ ២០០៨, កថាខណ្ឌ ៣៥)។

[៣០] ដីកាដំណោះស្រាយ, ឯកសារ D427, ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០១០, កថាខណ្ឌ ១៥៧៤។

00743446



ផ្នែកសេចក្តីសម្រេចបញ្ជូនបញ្ចប់នៃដីកាដំណោះស្រាយ[៣១]។ ទាំងនៅក្នុងដីកាដំណោះស្រាយ ទាំងសាលដីការបស់អង្គបុរេជំនុំជម្រះសុទ្ធតែពុំបានបង្ហាញអំពីថាតើជនជាប់ចោទអាចត្រូវបានដាក់ឱ្យទទួលខុសត្រូវចំពោះបទឧក្រិដ្ឋតាមច្បាប់ជាតិ ក្នុងនាមជាសមាជិកនៃសហឧក្រិដ្ឋកម្មរួម ឬជាថ្នាក់លើដោយរបៀបណានោះទេ[៣២]។

---

[៣១] ដីកាដំណោះស្រាយ, ឯកសារ D427, ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០១០, កថាខណ្ឌ ១៦១៣។ ប៉ុន្តែ ការវិភាគទូលំទូលាយនៃដីកាដំណោះស្រាយអំពីសហឧក្រិដ្ឋកម្មរួមត្រង់កថាខណ្ឌ ១៥២១-១៥៤២ ពុំបានលើកឡើងអំពីបទល្មើសក្រោមច្បាប់ជាតិឡើយ ដោយអនុលោមតាមដីកាសម្រេចរបស់ ស.ច.ស អំពីការអនុវត្តនៅ អ.វ.ត.ក នូវទម្រង់នៃការទទួលខុសត្រូវដែលត្រូវបានស្គាល់ថាជាសហឧក្រិដ្ឋកម្មរួម, ឯកសារ D97/13, ចុះថ្ងៃទី ០៨ ខែ ធ្នូ ឆ្នាំ ២០០៩ កថាខណ្ឌ ២២ (ដែលបានយល់ឃើញថា "ទម្រង់នៃការទទួលខុសត្រូវសម្រាប់បទល្មើសក្រោមច្បាប់អន្តរជាតិ អាចយកមកអនុវត្តតែចំពោះ...បទល្មើស ក្រោមច្បាប់អន្តរជាតិប៉ុណ្ណោះ")។ អង្គបុរេជំនុំជម្រះក៏ធ្លាប់បានសន្និដ្ឋានថា "គ្មានទឡ្ហីករណ៍ណាមួយក្នុងចំណោមទឡ្ហីករណ៍ដែលបានលើកឡើងដោយភាគីនានានៅក្នុងបណ្តឹងឧទ្ធរណ៍នេះបង្ហាញថាដីកាដែលត្រូវបានជំទាស់ ភាន់ច្រឡំក្នុងការពិចារណាថាទម្រង់សហឧក្រិដ្ឋកម្មរួមដែលជាទម្រង់នៃការទទួលខុសត្រូវមួយ ដែលត្រូវបានទទួលស្គាល់នៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ ត្រូវអនុវត្តចំពោះឧក្រិដ្ឋកម្មអន្តរជាតិទាំងឡាយ ជាជាងអនុវត្តចំពោះបទល្មើសជាតិនោះទេ" (សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតចំពោះការអនុវត្តសហឧក្រិដ្ឋកម្មរួម, អង្គបុរេជំនុំជម្រះ, ឯកសារ D97/15/9, ចុះថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ២០១០, កថាខណ្ឌ ១០២)។ ក៏ប៉ុន្តែ ផ្អែកតាមការប្រព្រឹត្តិបទល្មើសតាមរយៈសហឧក្រិដ្ឋកម្មរួម និងការទទួលខុសត្រូវរបស់ថ្នាក់លើ ផ្នែកសេចក្តីសម្រេចបញ្ចប់នៃដីកាដំណោះស្រាយចោទប្រកាន់ជនជាប់ចោទទាំងអស់ពីបទរំលោភក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦ ក្នុងចំណោមបទល្មើសផ្សេងៗ (ដីកាដំណោះស្រាយ, លេខឯកសារ D427, ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០១០, កថាខណ្ឌ ១៦១៣)។

[៣២] *សូមមើល ឧទាហរណ៍* សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ, ឯកសារ D427/1/30, ចុះថ្ងៃទី ១១ ខែ មេសា ឆ្នាំ ២០១១, កថាខណ្ឌ២៩៦ (ដែលផ្ទុយទៅវិញ អង្គបុរេជំនុំជម្រះគូសបញ្ជាក់ថា ការទទួលខុសត្រូវដែលត្រូវបានចោទប្រកាន់មកលើជនជាប់ចោទគឺផ្អែកទៅលើទម្រង់នានានៃការទទួលខុសត្រូវ "ដោយពុំនិយាយដល់ទម្រង់នៃការទទួលខុសត្រូវដែលសហចៅក្រមស៊ើបអង្កេតបាននិយាយថា ជាទម្រង់នៃការទទួលខុសត្រូវក្រោមច្បាប់អន្តរជាតិ ដូចជាការប្រព្រឹត្តបទល្មើសតាមរយៈសហឧក្រិដ្ឋកម្មរួម ការទទួលខុសត្រូវក្នុងនាមជាថ្នាក់លើ និងការញុះញង់ ដែលមិនត្រូវយកមកអនុវត្តចំពោះបទល្មើសក្រោមច្បាប់ជាតិ")។ ទាំងដីកាដំណោះស្រាយ និងសាលដីកាខាងលើរបស់អង្គជំនុំជម្រះសុទ្ធតែពុំបានបញ្ជាក់ច្បាស់ ថាតើត្រូវចាត់ទុកថាការទទួលខុសត្រូវក្នុងនាមជាថ្នាក់លើ អាចយកមកអនុវត្តបានចំពោះបទល្មើសក្រោមច្បាប់ជាតិដែរ ឬទេ (*សូមមើលឧទាហរណ៍* ដីកាដំណោះស្រាយ, ឯកសារ D427, ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០១០, កថាខណ្ឌ ១៣០៧ (ដែលបានទទួលស្គាល់ថាការទទួលខុសត្រូវ ក្នុងនាមជាថ្នាក់លើពុំត្រូវដាក់បញ្ចូលទៅក្នុងក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦ មែន ប៉ុន្តែគោលការណ៍នេះបានផ្សព្វផ្សាយទូលំទូលាយ និងគ្រប់គ្រាន់ដល់ជនត្រូវចោទ"), កថាខណ្ឌ ១៥៥៧-១៥៦៣ (ដោយយោងទៅលើតែបទល្មើសក្រោមច្បាប់ជាតិ ពាក់ព័ន្ធនឹងការវិភាគទូលំទូលាយរបស់ ស.ច.ស អំពីការទទួលខុសត្រូវក្នុងនាមជាថ្នាក់លើតែប៉ុណ្ណោះ) ហើយកថាខណ្ឌ ១៦១៣ (ដោយបញ្ជូនជនជាប់ចោទទៅជំនុំជម្រះដោយផ្អែកទៅលើការទទួលខុសត្រូវក្នុងនាមជាថ្នាក់លើពាក់ព័ន្ធនឹងបទល្មើសទាំងអស់)។ អង្គបុរេជំនុំជម្រះពុំបានលើកយកឯកសារយោងណាមួយមកធ្វើជាសំអាងឡើយ ចំពោះការ

១៦. អង្គជំនុំជម្រះសាលាដំបូងឯកភាពទៅនឹងសហព្រះរាជអាជ្ញា ត្រង់ចំណុចថា សំណើសុំលុប ឬកែប្រែផ្នែកខ្លះនៃដីកាដំណោះស្រាយ មិនមានចែងជាទូទៅនៅក្នុងក្របខ័ណ្ឌគតិយុត្តរបស់ អ.វ.ត.ក ទេ[៣៣]។ ក៏ប៉ុន្តែ អង្គជំនុំជម្រះក៏បានកត់សម្គាល់ឃើញថា ដីកាដំណោះស្រាយ ត្រង់ផ្នែកពាក់ព័ន្ធនឹងបទឧក្រិដ្ឋតាមច្បាប់ជាតិ ពុំបានបំពេញតាមបុរេលក្ខខណ្ឌសម្រាប់ឱ្យដីកានេះមានសុពលភាពដូចមានចែងក្នុងវិធាន ៦៧(២) នៃវិធានផ្ទៃក្នុងឡើយ[៣៤]។ បុរេលក្ខខណ្ឌទាំងនោះត្រូវបានបង្កើតឡើងដើម្បីការពារសិទ្ធិជាសារវ័ន្តរបស់ជនជាប់ចោទ ក្នុងការទទួលបានការជំនុំជម្រះក្ដីដោយយុត្តិធម៌ មានសិទ្ធិដឹងអំពីប្រភេទនៃបទល្មើស និងមូលហេតុនៃការចោទប្រកាន់មកលើខ្លួន និងមានឱកាសគ្រប់គ្រាន់ដើម្បីរៀបចំការការពារខ្លួន[៣៥]។

### *៤.១.១ បទដ្ឋានអន្តរជាតិជាធរមានពាក់ព័ន្ធនឹងទម្រង់នៃដីកាដំណោះស្រាយ*

១៧. កង្វល់ទាំងអស់នេះបង្ហាញកាន់តែច្បាស់ តាមរយៈការយោងទៅលើបទដ្ឋានដែលមាននៅក្នុងយុត្តិសាស្ត្រអន្តរជាតិ ពាក់ព័ន្ធនឹងលក្ខណៈជាក់លាក់ដែលតម្រូវឱ្យមាននៅក្នុងដីកាដំណោះស្រាយ[៣៦]។

---

ពុំបានដាក់បញ្ចូលការទទួលខុសត្រូវក្នុងនាមជាថ្នាក់លើ ទៅក្នុងបណ្ដុំនៃទម្រង់នៃការទទួលខុសត្រូវជាធរមានចំពោះបទឧក្រិដ្ឋតាមច្បាប់ជាតិ (សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ, ឯកសារ D427/1/30, ចុះថ្ងៃទី ១១ ខែ មេសា ឆ្នាំ ២០១១, កថាខណ្ឌ ២៨៦)។

[៣៣] ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងញត្តិរបស់ អៀង សារី ស្នើសុំលុបចោលផ្នែកខ្លះនៃដីកាដំណោះស្រាយ ដោយសារកំហុសផ្នែកនីតិវិធី, កថាខណ្ឌ ៣។

[៣៤] វិធាន៦៧(២) នៃវិធានផ្ទៃក្នុងចែងថាដីកាបញ្ជូនរឿងទៅជំនុំជម្រះ "ត្រូវបញ្ជាក់អំពីអត្តសញ្ញាណនៃជនជាប់ចោទ ការបង្ហាញអំពីអង្គហេតុ និងការកំណត់ប្រភេទបទល្មើសដោយសហចៅក្រមស៊ើបអង្កេត ក្នុងនោះមានទាំងបទប្បញ្ញត្តិនៃបទឧក្រិដ្ឋដែលពាក់ព័ន្ធ និងប្រភេទនៃការទទួលខុសត្រូវព្រហ្មទណ្ឌ បើពុំនោះសោត ដីកានេះត្រូវចាត់ទុកជាមោឃៈដោយសារកំហុសនីតិវិធី"។

[៣៥] នៅក្នុងបរិបទ អ.វ.ត.ក ការបញ្ជាក់ច្បាស់លាស់អំពីការចោទប្រកាន់នៅក្នុងដីកាដំណោះស្រាយនេះ គឺពាក់ព័ន្ធបន្តទៅទៀតជាមួយនឹងការសម្រេចជាស្ថាពរទៅលើការទាមទារសំណងរបស់ដើមបណ្ដឹងរដ្ឋប្បវេណី (*សូមមើលឧទាហរណ៍* វិធានផ្ទៃក្នុងត្រង់វិធាន២៣ស្ទួនបួន(១)(ក)(ដែលបានបញ្ជាក់ថា ទទួលស្គាល់នូវការខូចខាតដែលដើមបណ្ដឹងរដ្ឋប្បវេណីទទួលរងដោយសារការប្រព្រឹត្តិនូវបទឧក្រិដ្ឋរបស់ជនជាប់ចោទដែលត្រូវបានផ្ដន្ទាទោស")។ ការបញ្ជាក់ច្បាស់លាស់អំពីការចោទប្រកាន់អាចជូនដំណឹងដល់អង្គជំនុំជម្រះសាលាដំបូងឱ្យបានដឹងអំពីវិសាលភាពនៃសំណុំរឿងដែលខ្លួនបានទទួល និងបទល្មើសជាក់លាក់ដែលត្រូវជំនុំជម្រះ (*សូមមើលឧទាហរណ៍* វិធាន៦៧(៤)នៃវិធានផ្ទៃក្នុង (ដែលបានកត់សម្គាល់ថាដីកាដំណោះស្រាយ "បញ្ជូនរឿងទៅជំនុំជម្រះចំពោះអំពើមួយចំនួន ឬប្រឆាំងនឹងបុគ្គលមួយចំនួន [ឬ] លើកលែងការចោទប្រកាន់ចំពោះករណីដទៃទៀត")។

[៣៦] *សូមមើល* មាត្រា៣៣(ថ្មី) នៃច្បាប់ស្ដីពីការបង្កើត អ.វ.ត.ក (ដែលអនុញ្ញាតឱ្យមានការពឹងផ្អែកលើបទដ្ឋាននីតិវិធីដែលបានបង្កើតឡើងក្នុងកម្រិតអន្តរជាតិ នៅពេលវិធាននីតិវិធីកម្ពុជាដែលមានស្រាប់ ពុំមាននិយាយពាក់ព័ន្ធនឹងបញ្ហាណាមួយជាក់លាក់

១៨. ដូចច្បាប់យុត្តិសាស្ត្រនេះបានកត់សម្គាល់ គឺថាក្រៅពីជាមូលដ្ឋាននៃសំណុំរឿងប្រឆាំងនឹងជនជាប់ចោទ ដីកាដំណោះស្រាយ មានគោលបំណងជូនដំណឹងដល់ជនជាប់ចោទឱ្យបានដឹងអំពីសំណុំរឿងប្រឆាំងមកលើខ្លួន និងដើម្បីការពារសិទ្ធិរបស់ជនជាប់ចោទក្នុងការទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌ (ពិសេសគឺ សិទ្ធិរបស់ជនជាប់ចោទក្នុងការបានដឹងអំពីប្រភេទនៃបទល្មើស និងមូលហេតុនៃការចោទប្រកាន់មកលើខ្លួន និងមានពេលវេលា និងមធ្យោបាយគ្រប់គ្រាន់ដើម្បីរៀបចំការការពារខ្លួន)[៣៧]។ សិទ្ធិនេះក្លាយទៅជាកាតព្វកិច្ចមួយដែលតម្រូវឱ្យអង្គហេតុសំខាន់ៗ ដែលជាមូលដ្ឋាននៃការចោទប្រកាន់ដែលនឹងត្រូវដាក់បញ្ចូលទៅក្នុងដីកាដំណោះស្រាយ ត្រូវមានភាពលម្អិតជាក់លាក់គ្រប់គ្រាន់ដើម្បីឱ្យជនជាប់ចោទដឹងច្បាស់អំពីប្រភេទនៃបទល្មើស និងមូលហេតុនៃការចោទប្រកាន់មកលើខ្លួន។ ត្រង់នេះអាចធ្វើឱ្យជនជាប់ចោទមានលទ្ធភាពរៀបចំការការពារខ្លួនប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធផល[៣៨]។

១៩. អង្គហេតុមូលដ្ឋានត្រូវបានកំណត់ថាជាអង្គហេតុដែលយកមកធ្វើជាមូលដ្ឋាននៃសាលក្រម[៣៩]។ អង្គហេតុណាមួយដែលត្រូវបានកំណត់ថា ជាអង្គហេតុមូលដ្ឋាន វាអាស្រ័យទៅលើលក្ខណៈនៃសំណុំរឿងប្រឆាំងមកលើជនជាប់ចោទ[៤០]។ ប្រសិនបើដីកាដំណោះស្រាយដែលជាលិខិតុបករណ៍

---

និងនៅពេលមានមន្ទិលពាក់ព័ន្ធនឹងការបកស្រាយ ឬការអនុវត្ត វិធាននីតិវិធីទាំងនោះ ឬមានបញ្ហាចោទទាក់ទិននឹងភាពសមស្របរវាងវិធាននីតិវិធីជាតិ ជាមួយបទដ្ឋាននីតិវិធីអន្តរជាតិ)។

[៣៧] *សំណុំរឿង រដ្ឋអាជ្ញា ទល់នឹង* *Pavkovic,* លេខសំណុំរឿង IT-03-70-PT, សេចក្តីសម្រេចលើញត្តិបឋមរបស់ Vladimir Lazarević ពាក់ព័ន្ធនឹងទម្រង់នៃដីកាដំណោះស្រាយ, អង្គជំនុំជម្រះសាលាដំបូង, ចុះថ្ងៃទី ០៨ ខែ កក្កដា ឆ្នាំ ២០០៥, កថាខណ្ឌ ៩។

[៣៨] *សំណុំរឿង រដ្ឋអាជ្ញា ទល់នឹង* *Kupreskic,* លេខសំណុំរឿង IT-95-16-A, អង្គជំនុំជម្រះតុលាការកំពូល, ចុះថ្ងៃទី ២៣ ខែ តុលា ឆ្នាំ ២០០១, កថាខណ្ឌ ៨៨ (ដោយចង្អុលបញ្ជាក់ទៀតថាអ្វីដែលត្រូវបញ្ជាក់ឱ្យបានច្បាស់លាស់នៅក្នុងដីកាដំណោះស្រាយ គឺជាអង្គហេតុពាក់ព័ន្ធសំខាន់ៗ ពុំមែនភស្តុតាងដែលបញ្ជាក់អំពីអង្គហេតុទាំងអស់នោះឡើយ)។

[៣៩] *សំណុំរឿង រដ្ឋអាជ្ញា ទល់នឹង* *Kupreskic,* លេខសំណុំរឿង IT-95-16-A, អង្គជំនុំជម្រះតុលាការកពូល, ចុះថ្ងៃទី ២៣ ខែ តុលា ឆ្នាំ ២០០១, កថាខណ្ឌ ៨៨។

[៤០] បញ្ហាថាតើអង្គហេតុណាមួយជាអង្គហេតុសំខាន់ អាស្រ័យទៅលើវត្តមានរបស់ជនជាប់ចោទនៅក្នុងហេតុការណ៍បទល្មើសដែលត្រូវបានចោទថា ជនជាប់ចោទជាអ្នកទទួលខុសត្រូវផ្ទែកព្រហ្មទណ្ឌ។ *សូមមើលឧទាហរណ៍ សំណុំរឿង រដ្ឋអាជ្ញា ទល់នឹង* *Kvocka,* លេខសំណុំរឿង IT-98030/1-A, អង្គជំនុំជម្រះតុលាការកំពូល, ចុះថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ ២០០៥, កថាខណ្ឌ ៦៥ ("នៅពេលដែលជនជាប់ចោទស្ថិតនៅឆ្ងាយពីហេតុការណ៍បទល្មើស គេពុំត្រូវការអង្គហេតុច្បាស់លាស់ លម្អិតពាក់ព័ន្ធនឹងហេតុការណ៍បទល្មើសនោះឡើយ ហើយគេផ្តោតសំខាន់ទៅលើទង្វើរបស់ជនជាប់ចោទ ដែលជាមូលដ្ឋាននៃការទទួលខុសត្រូវរបស់

ចោទប្រកាន់ដ៏សំខាន់ដំបូងមិនបានដាក់បញ្ចូលសេចក្តីលម្អិតគ្រប់គ្រាន់នូវចំណុចសំខាន់ៗនៃសំណុំរឿងប្រឆាំងនឹងជនជាប់ចោទទេនោះ ពេលនោះដីកានោះពិតជាមានវិការៈធ្ងន់ធ្ងរ[៤១]។ ជាងនេះទៅទៀត វាជាការមិនគ្រប់គ្រាន់ឡើយសម្រាប់ដីកាដំណោះស្រាយមួយដែលគ្រាន់តែតម្កល់នូវការជឿជាក់របស់ខ្លួនលើទម្រង់នីមួយៗនៃការទទួលខុសត្រូវដែលត្រូវបានចោទប្រកាន់ចំពោះបទចោទទាំងអស់ដែលបានចោទប្រកាន់នៅក្នុងដីកាដំណោះស្រាយ ដោយមិនបានបង្ហាញនូវអំពើនានាដែលត្រូវបានចោទប្រកាន់ពាក់ព័ន្ធនឹងប្រភេទនៃការទទួលខុសត្រូវនោះ[៤២]។ ប៉ុន្តែដីកាដំណោះស្រាយអាចចោទប្រកាន់ជនជាប់ចោទបានអំពីរាល់ទម្រង់ទាំងអស់នៃការទទួលខុសត្រូវបានដរាបណាអង្គហេតុសំខាន់ពាក់ព័ន្ធនឹងទម្រង់នីមួយៗត្រូវបានដាក់បញ្ចូលទៅក្នុងដីកាដំណោះស្រាយប៉ុណ្ណោះ[៤៣]។

២០. នាពេលថ្មីៗនេះ អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់រ៉្វាន់ដា (“ICTR”) និងតុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់យូហ្គោស្លាវី (“ICTY”) បានប្រកាន់យកវិធីសាស្ត្រម៉ឺងម៉ាត់ជាងមុន ចំពោះការកម្រិតនៃភាពលម្អិតជាក់លាក់នៃអង្គហេតុសំខាន់ៗដែលត្រូវដាក់បញ្ចូលទៅក្នុងដីកាដំណោះស្រាយ។ តុលាការខាងលើក៏បានយកវិធីសាស្ត្រនេះទៅអនុវត្តក្នុងការចោទប្រកាន់ទៅលើអំពើ និងការប្រព្រឹត្តិរបស់ជនជាប់ចោទ ដែលបង្កើតជាមូលដ្ឋាននៃការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ជនជាប់ចោទផងដែរ[៤៤]។

---

គាត់ក្នុងនាមជាអ្នកសមគំនិត ឬថ្នាក់លើ ចំពោះជនដែលបានប្រព្រឹត្តដោយផ្ទាល់នូវអំពើដែលនាំទៅដល់ការចោទប្រកាន់មកលើខ្លួន”។

[៤១] *សំណុំរឿង រដ្ឋអាជ្ញា ទល់នឹង Pavkovic,* លេខសំណុំរឿង IT-03-70-PT, សេចក្តីសម្រេចលើញត្តិបឋមរបស់ Vladimir Lazarević ពាក់ព័ន្ធនឹងទម្រង់នៃដីកាដំណោះស្រាយ, អង្គជំនុំជម្រះសាលាដំបូង, ចុះថ្ងៃទី ០៨ ខែ កក្កដា ឆ្នាំ ២០០៥, កថាខណ្ឌ ៦។

[៤២] *សូមមើលឧទាហរណ៍ រដ្ឋអាជ្ញា ទល់នឹង Blaskic,* លេខសំណុំរឿង IT-95-14-A, សាលដីកា, អង្គជំនុំជម្រះតុលាការកំពូល, ចុះថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ២០០៤, កថាខណ្ឌ ២២៦។

[៤៣] *សំណុំរឿង រដ្ឋអាជ្ញា ទល់នឹង Kvocka,* លេខសំណុំរឿង IT-98-30/1-A, អង្គជំនុំជម្រះតុលាការកំពូល, ចុះថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ ២០០៥, កថាខណ្ឌ ២៩។

[៤៤] ត្រង់ចំណុចដែលមានការយល់ឃើញថា ដីកាដំណោះស្រាយពុំបានជូនដំណឹងឲ្យជនជាប់ចោទបានដឹងច្បាស់លាស់អំពីប្រភេទបទល្មើស និងមូលហេតុនៃការចោទប្រកាន់ណាមួយមកលើខ្លួន អង្គជំនុំជម្រះតុលាការ ICTY និងតុលាការ ICTR តែងបានបង្គាប់ឲ្យមានការកែប្រែផ្នែកខ្លះនៃដីកានេះ ឬបង្គាប់ឲ្យរដ្ឋអាជ្ញាបញ្ជាក់ឲ្យបានច្បាស់ទៅលើចំណុចអង្គហេតុណាមួយដែលពួកគេចង់លើកយកមកធ្វើជាសំអាងដើម្បីដាក់ឲ្យជនជាប់ចោទទទួលខុសត្រូវលើបទល្មើសនីមួយៗ។ *សូមមើលឧទាហរណ៍ រដ្ឋអាជ្ញា ទល់នឹង Pavkovic, លេខសំណុំរឿង* IT-03-70-PT, សេចក្តីសម្រេចលើញត្តិបឋមរបស់ Vladimir Lazarević ពាក់ព័ន្ធនឹង

សេចក្តីសម្រេចលើអញ្ញត្រកម្មនានាស្តីពីអាជ្ញាយុកាលនៃបទឧក្រិដ្ឋតាមច្បាប់ជាតិ/ថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ២០១១/ 

២១. នៅក្នុងដីកាដំណោះស្រាយ អង្គជំនុំជម្រះកត់សម្គាល់ឃើញថា ពុំមានការយោងទៅលើអង្គហេតុជាក់លាក់ ឬទម្រង់នៃការទទួលខុសត្រូវនានាដែលត្រូវបានចោទប្រកាន់ពាក់ព័ន្ធនឹងបទឧក្រិដ្ឋតាមច្បាប់ជាតិ ដែលមាននៅក្នុងដីកាដំណោះស្រាយឡើយ។ បើទោះបីជាអង្គជំនុំជម្រះឯកភាពជាមួយ ក.ស.ព ត្រង់ចំណុចដែលថាការចោទប្រកាន់បទល្មើសត្រួត ឬការចោទប្រកាន់បទល្មើសផ្សេងគ្នាពាក់ព័ន្ធនឹងអង្គហេតុតែមួយ ត្រូវបាន អ.វ.ត.ក និងតុលាការអន្តរជាតិផ្សេងទៀតគាំទ្រក្តី ក៏ដីកាដំណោះស្រាយពុំបានបញ្ជាក់ច្បាស់លាស់ ថាតើបទល្មើសទាំងអស់នេះផ្អែកលើមូលដ្ឋានអង្គហេតុតែមួយដូចបទល្មើសផ្សេងទៀត ឬយ៉ាងណានោះទេ។ ហើយប្រសិនបើសំអាងលើមូលដ្ឋានអង្គហេតុតែមួយមែន តើបទល្មើស និងអង្គហេតុពាក់ព័ន្ធណាមួយដែលមានជាប់ពាក់ព័ន្ធទៅនឹងបទឧក្រិដ្ឋតាមច្បាប់ជាតិដែលត្រូវបានចោទប្រកាន់។ លើសពីនេះ ដីកាដំណោះស្រាយបញ្ជាក់ថា បទឧក្រិដ្ឋតាមច្បាប់ជាតិមិនដូចទៅនឹងបទល្មើសក្រោមច្បាប់អន្តរជាតិដែលស្រដៀងៗគ្នានេះឡើយ។ ប៉ុន្តែដីកានេះពុំបានបញ្ជាក់លម្អិត ថាតើអង្គហេតុដែលចោទប្រកាន់ ឬទម្រង់នៃការទទួលខុសត្រូវពាក់ព័ន្ធនឹងបទល្មើសទាំងនេះ មានចំណុចខុសគ្នាដោយសារ "ធាតុផ្សំសំខាន់ៗ" ដូចម្តេច ទើបធ្វើឱ្យបទឧក្រិដ្ឋតាមច្បាប់ជាតិខុសពីបទល្មើសក្រោមច្បាប់អន្តរជាតិនោះ[៤៥]។

២២. អង្គជំនុំជម្រះយល់ឃើញថា នៅក្នុងបរិបទនីតិវិធីចំពោះមុខ អ.វ.ត.ក វិការៈទាំងអស់នេះពុំអាចជួសជុលតាមរយៈការកែប្រែផ្នែកខ្លះនៃដីកាដំណោះស្រាយពីសំណាក់អង្គជំនុំជម្រះសាលាដំបូងបានឡើយ [៤៦]។ ក្របខ័ណ្ឌគតិយុត្តិរបស់ អ.វ.ត.ក ក៏មិនបានអនុញ្ញាតឱ្យបញ្ជូនដីកាដំណោះស្រាយ

---

ទម្រង់នៃដីកាដំណោះស្រាយ, អង្គជំនុំជម្រះសាលាដំបូង, ចុះថ្ងៃទី ០៨ ខែ កក្កដា ឆ្នាំ ២០០៥, កថាខណ្ឌ ២១, ២៦ និងផ្នែកសេចក្តីសម្រេចបញ្ចប់។

[៤៥] ដីកាដំណោះស្រាយ, ឯកសារ D427, ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០១០, កថាខណ្ឌ ១៥៦៥ (លុបចោលអត្ថបទសម្រង់) ប្រៀបធៀបទៅនឹង កថាខណ្ឌ ១៥៧៤ (ត្រង់ចំណុចដែល ស.ច.ស បានសម្តែងមន្ទិលថាតើជនជាប់ចោទអាចត្រូវបានចោទប្រកាន់ពីបទឧក្រិដ្ឋតាមច្បាប់ជាតិផង និងអន្តរជាតិផង ដោយពុំរំលោភលើសិទ្ធិរបស់ពួកគាត់ក្នុងការពុំទទួលការកាត់សេចក្តីពីរដងលើអង្គហេតុតែមួយ)។

[៤៦] *សូមមើល* វិធាន ៧៦(៧) នៃវិធានផ្ទៃក្នុង (គ្មានបញ្ហាណាមួយដែលពាក់ព័ន្ធនឹងកំហុសនីតិវិធីក្នុងដីកាដំណោះស្រាយ អាចត្រូវបានលើកឡើងនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ឬអង្គជំនុំជម្រះតុលាការកំពូលឡើយ)។ និងវិធាន ៧៩(១) (ដែលបានចែងថាអង្គជំនុំជម្រះសាលាដំបូងទទួលបណ្តឹងដោយដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់សហចៅក្រមស៊ើបអង្កេត ឬតាមសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះ) (*ប្រៀបធៀបទៅនឹង* នីតិវិធីកែតម្រូវដែលត្រូវបានអនុវត្តនៅចំពោះមុខតុលាការ *មិនអចិន្ត្រៃយ៍* (*សូមមើលខាងលើ,* ជើងទំព័រ ៤៤))។ ដោយយោងទៅលើលក្ខណៈជាសារវ័ន្តនៃវិការៈដូចដែលបានចោទប្រកាន់នៅក្នុងដីកាដំណោះស្រាយ អង្គជំនុំជម្រះក៏យល់ឃើញផងដែរថាបញ្ហាកង្វះភាពច្បាស់លាស់នេះ ពុំអាចជួសជុលបានឡើយតាមរយៈការផ្តល់

ស្ដាពរត្រឡប់ទៅ ស.ច.ស វិញដែរ។ ក្នុងករណីណាក៏ដោយ ក្នុងស្ថានភាពបច្ចុប្បន្ន ទង្វើនេះជាការរំលោភសិទ្ធិរបស់ជនជាប់ចោទក្នុងការទទួលបានការជំនុំជម្រះក្ដីដោយឆាប់រហ័ស និងពុំអាចធ្វើទៅបានឡើយ។ ខណៈដែលអង្គជំនុំជម្រះសាលាដំបូងត្រូវសម្រេចអំពីវិសាលភាពនៃសំណុំរឿងដែលខ្លួនបានទទួលនោះ វិការៈដែលមាននៅក្នុងដីកាដំណោះស្រាយពាក់ព័ន្ធនឹងបទឧក្រិដ្ឋតាមច្បាប់ជាតិដូចបានរៀបរាប់ខាងលើ គឺជាបច្ច័យធ្វើឱ្យអង្គជំនុំជម្រះពុំអាចកំណត់បាននូវខ្លឹមសារនៃការចោទប្រកាន់អំពីបទឧក្រិដ្ឋតាមច្បាប់ជាតិទាំងនេះមូលដ្ឋានសំអាងហេតុ និងមូល ដ្ឋានគតិយុត្តិនៃការកំណត់បទចោទដែលមាននៅក្នុងដីកាដំណោះស្រាយ។ ហេតុដូច្នេះ អង្គជំនុំជម្រះសាលាដំបូងមិនអាចសម្រេចអំពីវិសាលភាពនៃសំណុំរឿងដែលខ្លួនបានទទួលនេះទេ ដោយ សារតែមានការរំលោភសិទ្ធិការពារខ្លួនរបស់ជនជាប់ចោទយ៉ាងជាក់ច្បាស់ដូច្នេះ។ ក្នុងការអនុវត្តភារកិច្ចរបស់ខ្លួនដើម្បីធានាការគោរពសិទ្ធិជាសារវ័ន្តរបស់ជនជាប់ចោទ និងភាពត្រឹមត្រូវនៃកិច្ចដំណើរការនីតិវិធី អង្គជំនុំជម្រះគ្មានជម្រើសអ្វីក្រៅពីប្រកាសថា អង្គជំនុំជម្រះបានទទួលសំណុំ រឿងដែលពុំមានសុពលភាព ពាក់ព័ន្ធនឹងការចោទប្រកាន់លើបទល្មើសនានាដែលមាននៅក្នុងក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦ ដូចមានរៀបរាប់ក្នុងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០២។

២៣. អាស្រ័យហេតុនេះ អង្គជំនុំជម្រះសម្រេចថា ការចោទប្រកាន់ទាំងឡាយនៅក្នុងដីកាដំណោះស្រាយពាក់ព័ន្ធនឹងបទល្មើសដែលមាននៅក្នុងក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦ ពុំអាចបង្កើតជាមូលដ្ឋានដើម្បីជំនុំជម្រះនៅចំពោះមុខ អ.វ.ត.ក បានឡើយ។ បន្ទាប់ពីបានសម្រេចថា ការជំនុំជម្រះលើបទឧក្រិដ្ឋតាមច្បាប់ជាតិពុំអាចប្រព្រឹត្តទៅបានដោយហេតុថាដីកាដំណោះស្រាយមានវិការៈនោះ អង្គជំនុំ-ជម្រះយល់ឃើញថា អង្គជំនុំជម្រះពុំចាំបាច់សម្រេចអំពីយុត្តាធិការរបស់ អ.វ.ត.ក ចំពោះបទឧក្រិដ្ឋតាមច្បាប់ជាតិនោះទេ។

## សេចក្ដីសម្រេច

## តាមសំអាងហេតុដូចដែលបានបញ្ជាក់ខាងលើ អង្គជំនុំជម្រះសាលាដំបូង

**ប្រកាសថា** អង្គជំនុំជម្រះបានទទួលសំណុំរឿងដែលពុំមានសុពលភាពពាក់ព័ន្ធនឹងការចោទប្រកាន់លើបទល្មើសនានាតាមក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦ ដូចមានរៀបរាប់ក្នុងផ្នែកសេចក្ដីសម្រេចបញ្ចប់ត្រង់កថា-ខណ្ឌ ១៦១៣ នៃដីកាដំណោះស្រាយក្នុងសំណុំរឿង ០០២។

---

សេចក្ដីលម្អិតជាក់លាក់ដោយសហព្រះរាជអាជ្ញា ពាក់ព័ន្ធនឹងអង្គហេតុសំខាន់ៗទាំងប៉ុន្មានដែលពួកគេមានបំណងលើកយកមកធ្វើជាសំអាង នៅក្នុងការបំពេញកាតព្វកិច្ចស្វែងរកភស្តុតាង ដែលពួកគេត្រូវធ្វើពាក់ព័ន្ធនឹងបទឧក្រិដ្ឋតាមច្បាប់ជាតិ។

**សម្រេចថា** អង្គជំនុំជម្រះពុំមានមូលដ្ឋានក្នុងការជំនុំជម្រះជនជាប់ចោទពីបទឧក្រិដ្ឋតាមច្បាប់ជាតិ ហើយការជំនុំជម្រះលើបទឧក្រិដ្ឋទាំងអស់នេះពុំអាចប្រព្រឹត្តទៅបានឡើយ។

**យល់ព្រម** តាមសំណើរបស់ អៀង សារី ដែលស្នើសុំលុបចោលពីដីកាដំណោះស្រាយនូវចំណុចពាក់ព័ន្ធទៅនឹងការជំនុំជម្រះលើបទឧក្រិដ្ឋតាមច្បាប់ជាតិនៅចំពោះមុខ អ.វ.ត.ក។

**សម្រេចថា** អង្គជំនុំជម្រះសាលាដំបូងពុំចាំបាច់សម្រេចទៅលើខ្លឹមសារនៃអញ្ញត្រកម្មផ្សេងទៀតរបស់មេធាវីការពារក្តីស្តីពីបទឧក្រិដ្ឋតាមច្បាប់ជាតិ និងបញ្ហាពាក់ព័ន្ធនានាឡើយ។

ភ្នំពេញ ថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ២០១១

ប្រធានអង្គជំនុំជម្រះសាលាដំបូង

និល ណុន